សាច់ប្រាក់ សម្រាប់ធ្វើការទូទាត់ជាទៀងទាត់ឲ្យកសិករ ហើយវិធីនេះ ក៏ជួយកែលំអលំហូរសាច់ប្រាក់របស់កសិករផងដែរ។ ចំណុចនេះអាចសម្រេចបាន តាមការពន្លឿន ការអនុវត្តគោលនយោបាយស្រូវបច្ចុប្បន្ននេះដែរ (RGC 2010)។

៥. **បង្កើតអង្គភាពថ្នាក់ក្រោមជាតិមួយ សម្រាប់ការពង្រឹងអនុវត្ត និងធ្វើច្បាប់គ្រប់គ្រងកិច្ចសន្យា៖** វិធីនេះអាចជួយឲ្យកសិករ និងសហគ្រាសកសិពាណិជ្ជកម្ម មានអំណាច តថ្លៃស្មើគ្នា និងជួយកាត់បន្ថយករណីបំពានលើកិច្ចសន្យាពីសំណាក់ភាគីណាមួយ។ ដើម្បីអាចដំណើរការដោយមានប្រសិទ្ធភាពល្អ អង្គភាពនេះគួរអនុញ្ញាតឲ្យកសិករមកទាក់ទងខ្លួនបាន និងគួរមានសមាសភាពមកពីទាំងបួនក្រុម គឺកសិករ អាជ្ញាធរមូលដ្ឋាន សហគ្រាសកសិពាណិជ្ជកម្ម និង MAFF (ដែលជាក្រសួងជាប់ពាក់ព័ន្ធ)។

## ឯកសារយោង

Cai, J., L.Ung, S.Setboonsarng and P. Leung (2008), “Rice Contract Farming in Cambodia: Empowering Farmers to Move beyond the Contract toward Independence”, ADBI Discussion Paper 109 (Tokyo: Asian Development Bank Institute)

Mund, Jan-Peter (2011), “The Agriculture Sector in Cambodia: Trends, Processes and Disparities”, *Pacific News,* No. 35, pp. 10-14

RGC, Royal Government of Cambodia (2010), *Policy Paper on the Promotion of Paddy Production and Rice Export* (Phnom Penh: Council of Ministers)

FAO/WFP, Food and Agriculture Organisation and World Food Programme (2012), *FAO/WFP Crop and Food Security Update Mission to Cambodia* (Rome: FAO and WFP)

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[1]

ផ្នែកនេះរៀបរាប់ពី សូចនាករសេដ្ឋកិច្ចសំខាន់ៗនៅក្នុងពិភពលោក នៅអាស៊ីខាងត្បូង និងអាស៊ីខាងកើត។

សេដ្ឋកិច្ចពិភពលោកហាក់កំពុងរើបឡើងវិញ ប៉ុន្តែភាពមិនប្រាកដប្រជា និងភាពងាយរងគ្រោះនៅតែកើតមានជាបន្ត ដោយសារសេដ្ឋកិច្ចប្រទេសឧស្សាហកម្មធំៗ នៅមានកំណើនយឺត និងបន្តឡើងចុះ។ តំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីខាងកើត នៅតែជាកម្លាំងជំរុញចម្បងនៃការរើបសេដ្ឋកិច្ចពិភពលោក ថ្វីបើប្រទេសខ្លះមានកំណើនយឺតជាងមុនក្ដី។

នៅត្រីមាសទី១ កំណើន ផសស ពិតនៅឥណ្ឌូនេស៊ីធ្លាក់ចុះបន្តិចមកត្រឹម ៥,៨% ធៀបនឹង ៦,០% កាលពីត្រីមាសមុន និង ៦,៤% កាលពីមួយឆ្នាំមុន។ កំណើន ផសស របស់ម៉ាឡេស៊ី កើនដល់ ៤,៣% ធៀបនឹង ៤,១% កាលពីត្រីមាសមុន ប៉ុន្តែធ្លាក់ចុះបើធៀបនឹងអត្រា ៥,៤% កាលពីមួយឆ្នាំមុន។ កំណើន ផសស នៅសិង្ហបុរី កើនខ្ពស់បំផុតគិតចាប់ពីឆ្នាំ២០១១ មក ដល់ ៣,៧% ធៀបនឹង ១,៩% កាលពីមួយឆ្នាំមុន។ សេដ្ឋកិច្ចប្រទេសចិន រីកលូតលាស់យឺតជាងមុនបន្តិច ប៉ុន្តែនៅតែមានកំណើនដ៏លឿនបំផុតមួយ ដោយមានអត្រាជាមធ្យម ៧,៦% សម្រាប់រយៈពេល ៥ត្រីមាសចុងក្រោយ។ ផសស ពិតរបស់ចិន នៅត្រីមាសទី២ ធ្លាក់ចុះបន្តិចមកត្រឹម ៧,៥% ធៀបនឹង ៧,៧% កាលពីត្រីមាសមុន និង ៧,៦% កាលពីឆ្នាំមុន។ មានការវាយស្មានថា សេដ្ឋកិច្ចចិនអាចកើនយឺតជាងមុន ប្រសិនបើចិនមិនធ្វើការកែតម្រូវរចនាសម្ព័ន្ធដ៏ចាំបាច់ៗនោះទេ។ បញ្ហាជាច្រើន ដូចជា អំពើពុករលួយរបស់មន្ត្រីជាន់ខ្ពស់, អប្រសិទ្ធភាពនៃសហគ្រាសរដ្ឋ និងបរិយាកាសអាជីវកម្មមានការរើសអើង ចំពោះវិនិយោគិនបរទេស គឺត្រូវតែដោះស្រាយ។ ប្រទេសចិនក៏ត្រូវស្វែងរកដំណោះស្រាយដោយសន្តិវិធីលើ បញ្ហាជម្លោះដណ្ដើមដែនកោះមួយចំនួន ដើម្បីកុំឲ្យវាឈានដល់ការប្រើសកម្មភាពយោធា ហើយខូចខាតដល់សេដ្ឋកិច្ច និងនយោបាយ។ កំណើន ផសស ពិតនៅហុងកុង កើនដល់ ៣,៣% ធៀបនឹង ២,៨% កាលពីត្រីមាសមុន ហើយកំណើន ផសស ពិតនៅកូរ៉េខាងត្បូង កើនដល់ ២,៣% ធៀបនឹង ១,៥% កាលពីត្រីមាសមុន។

នៅត្រីមាសទី២ ការរើបសេដ្ឋកិច្ចឡើងវិញនៅតំបន់អឺរ៉ូ នៅតែបន្តឡើងចុះ។ កំណើន ផសស បានរួមចុះមកដល់ ០,៧% ធៀបនឹង ១,១% កាលពីត្រីមាសទី១។ ភាពគ្មានការងារធ្វើ ជាពិសេសក្នុងចំណោមយុវជន នៅមានកម្រិតខ្ពស់នៅតាមបណ្ដាប្រទេស ដូចជា អេស្ប៉ាញ និង អ៊ីតាលី ជាដើម។ ការសម្រេចបានសមត្ថភាពប្រកួតប្រជែងក្នុងចំណោមប្រទេសជាសមាជិក ក៏ជាបញ្ហាប្រឈមមួយដែរ។ សេដ្ឋកិច្ចជប៉ុន មានកំណើនយឺតត្រឹម ០,៤% ធៀបនឹង ២,៨% កាលពីមួយឆ្នាំមុន។ សហរដ្ឋអាមេរិកបន្តមានដំណើរការសេដ្ឋកិច្ចល្អ បើធៀបនឹងប្រទេសមានសេដ្ឋកិច្ចជឿនលឿនដទៃទៀត ទោះបីកំណើនធ្លាក់ចុះបន្តិចនៅត្រីមាសទី២ មកត្រឹម ១,៤% ធៀបនឹង ១,៨% កាលពីត្រីមាសមុនក្ដី។

[1] អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

ប៉ុន្តែមានការវាយស្មានថា សហរដ្ឋអាមេរិក អាចរួមចុះសេដ្ឋកិច្ចម្តងទៀត ដោយសារមានការទាល់ច្រកផ្នែកនយោបាយលើបញ្ហាថវិកា និងការបង្កើនកម្រិតអតិបរមានៃបំណុល។ ការបិទសេវាកម្មរដ្ឋាភិបាលមួយចំនួន បានប៉ះពាល់ដល់អាជីវកម្មនានា ដោយកាត់បន្ថយចំណាយប្រើប្រាស់ផ្ទាល់ខ្លួន របស់មន្ត្រីដែលត្រូវគេផ្អាកពីការងារ។ បញ្ហានេះក៏អាចជះឥទ្ធិពលលើ ដំណើរការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកដែរ។

## អតិផរណាពិភពលោក និងអត្រាប្ដូរប្រាក់

អតិផរណានៅត្រីមាសទី២ មានលក្ខណៈសមរម្យនៅស្ទើរតែគ្រប់ប្រទេស។ នៅកម្ពុជាអតិផរណាឡើងដល់២,២%ធៀបនឹង១,៥% កាលពីត្រីមាសមុន ប៉ុន្តែវាធ្លាក់ចុះបើធៀបនឹងអត្រា២,៩%កាលពីមួយឆ្នាំមុន។ អតិផរណានៅវៀតណាមបន្តធ្លាក់ចុះមកដល់៦,៦% ធៀបនឹង ៨,៦% កាលពីមួយឆ្នាំមុន។ នៅជប៉ុនមានការធ្លាក់ចុះថ្លៃទំនិញសរុប ដែលបង្កជាសម្ពាធរុញឲ្យអត្រាការប្រាក់កើនឡើង។ បរិត្តផរណានៅតែបន្តកើតមាននៅជប៉ុន ទោះបីមានការចាប់ផ្តើមធ្វើចំណាយដ៏ច្រើនសម្បើម ស្របតាមគោលនយោបាយ **“Abenomics”** ក្តី។

នៅត្រីមាសទី២ ទល់នឹងប្រាក់ដុល្លារ ប្រាក់រៀលធ្លាក់ថ្លៃ ០,៩% ធៀបនឹងត្រីមាសមុន ប៉ុន្តែឡើងថ្លៃ ០,៥% ធៀបនឹងមួយឆ្នាំមុន។ ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ី ធ្លាក់ថ្លៃ ១,១% ធៀបនឹងត្រីមាសមុន (៥,៤% ធៀបនឹងមួយឆ្នាំមុន)។ ប្រាក់រីងហ្គីតម៉ាឡេស៊ី ឡើងថ្លៃ ៣,២% ធៀបនឹងត្រីមាសមុន។ ប្រាក់បាតថៃ ធ្លាក់ថ្លៃ ០,៣% ធៀបត្រីមាសមុន ប៉ុន្តែឡើងថ្លៃ ៤,៥% ធៀបមួយឆ្នាំមុន។ ប្រាក់អឺរ៉ូ នៅថេរ ប៉ុន្តែប្រាក់យេនជប៉ុន ធ្លាក់ថ្លៃ ៧,០% (២៣,៣% ធៀបមួយឆ្នាំមុន) ដែលបានជួយជំរុញថែមទៀតនូវភាពប្រកួតប្រជែងផ្នែកនាំចេញរបស់ជប៉ុន។

## ថ្លៃទំនិញលើទីផ្សារពិភពលោក

នៅត្រីមាសទី២ ពោតធ្លាក់ថ្លៃ ៤,៥% ធៀបនឹងត្រីមាសមុន មកនៅ ២៩១,៤ដុល្លារ/តោន ប៉ុន្តែឡើងថ្លៃ ៧,៧% បើធៀបមួយឆ្នាំមុន។ ប្រេងឆាធ្លាក់ថ្លៃ ០,៣% (២១,៥% ធៀបមួយឆ្នាំមុន) មកនៅ ៨៥០,៣ដុល្លារ/តោន ហើយកៅស៊ូធ្លាក់ថ្លៃ ១៧,៦% (២៥,៧% ធៀបមួយឆ្នាំមុន) មកនៅ ២៤៩៧ដុល្លារ/តោន។ នៅត្រីមាសដដែលនេះ អង្ករថៃធ្លាក់ថ្លៃ ៦,១% ធៀបត្រីមាសមុន (កើន ៥,០% ធៀបមួយឆ្នាំមុន) ដល់ ៥៧០ដុល្លារ/តោន ប៉ុន្តែសណ្តែកសៀងឡើងថ្លៃ ២,០% (៤,៣% ធៀបមួយឆ្នាំមុន) ដល់ ៥៦៩,៨ដុល្លារ/តោន។ ប្រេងនៅធ្លាក់ថ្លៃ ៧,៩% (៥,៤% ធៀបមួយឆ្នាំមុន) មកនៅ ១០០,៩ដុល្លារ/ធុង។ នៅសហរដ្ឋអាមេរិក សាំងធ្លាក់ថ្លៃ ៤,៨% ធៀបត្រីមាសមុន (៣,៨% ធៀបមួយឆ្នាំមុន) មកនៅ ០,៧១ដុល្លារ/លីត្រ ហើយម៉ាស៊ូតធ្លាក់ថ្លៃ ៧,២% (២,៨% ធៀបមួយឆ្នាំមុន) មកនៅ ០,៧៦ដុល្លារ/លីត្រ។ ការធ្លាក់ថ្លៃជារួមនៃទំនិញចម្បងៗ ព្រមទាំងប្រេងនៅ និងឧស្ម័ន បានបង្ហាញមួយចំណែក ពីការថយចុះចំណាយប្រើប្រាស់របស់ប្រទេសមានសេដ្ឋកិច្ចកំពុងផុសឡើង ដូចជា ចិន ជាដើម។ កិច្ចប្រឹងប្រែងរបស់សហរដ្ឋអាមេរិក ដើម្បីក្លាយជាប្រទេសឯករាជ្យផ្នែកថាមពល និងប្រែងនោះ អាចកាត់បន្ថយតម្រូវការប្រេង ហើយដាក់សម្ពាធឲ្យថ្លៃប្រេងធ្លាក់ចុះ។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៣ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2008 | 2009 | 2010 | 2011 | | | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 6.8 | 0.1 | - | - | - | - | - | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.1 | 4.2 | 6.2 | 6.5 | 6.5 | 6.5 | 6.3 | 6.4 | 6.2 | 6.1 | 6.0 | 5.8 |
| ម៉ាឡេស៊ី | 4.6 | -2.4 | 9.0 | 4.0 | 5.8 | 5.2 | 4.7 | 5.4 | 5.2 | 6.4 | 4.1 | 4.3 |
| សិង្ហបុរី | 1.1 | -4.5 | 14.7 | 0.9 | 5.9 | 3.6 | 1.6 | 1.9 | 0.3 | 1.5 | 0.2 | 3.7 |
| ថៃ | 2.6 | 3.3 | 7.9 | 2.6 | 3.5 | -9.0 | 0.0 | 4.2 | 3.3 | 19.5 | 5.4 | 2.6 |
| វៀតណាម | 6.2 | 4.7 | 6.7 | 5.7 | 7.2 | 6.1 | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 9.0 | 8.2 | 10.4 | 9.5 | 9.1 | 8.9 | 8.1 | 7.6 | 7.4 | 7.9 | 7.7 | 7.5 |
| ហុងកុង | 2.4 | -3.2 | 6.9 | 5.1 | 4.3 | 3.0 | 4.2 | 3.6 | 1.3 | 2.5 | 2.8 | 3.3 |
| កូរ៉េខាងត្បូង | 2.2 | -1.0 | 6.1 | 3.4 | 3.4 | 3.4 | 3.0 | 2.4 | 1.5 | 1.6 | 1.5 | 2.3 |
| តៃវ៉ាន់ | 0.1 | -3.6 | 11.1 | 4.9 | 3.4 | 1.9 | 0.4 | -0.2 | 1.0 | 3.7 | 1.7 | 2.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.9 | -3.8 | 1.6 | 1.6 | 1.4 | 0.7 | 0.0 | -0.4 | -0.6 | -0.9 | 1.1 | -0.7 |
| ជប៉ុន | -0.7 | -5.4 | 4.1 | -1.0 | 0.0 | -1.0 | 2.8 | 3.5 | 0.1 | 0.5 | 0.4 | 0.9 |
| សហរដ្ឋអាមេរិក | 1.1 | -2.5 | 2.7 | 1.5 | 1.6 | 1.6 | 2.1 | 2.2 | 2.5 | 1.6 | 1.8 | 1.4 |

Sources: IMF, Economist and countries’ statistic offices

## តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៣ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | | | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 19.7 | -0.5 | 4.1 | 6.2 | 6.7 | 4.9 | 5.5 | 2.9 | 1.6 | 1.8 | 1.5 | 2.2 |
| ឥណ្ឌូណេស៊ី | 10.1 | 4.7 | 5.1 | 5.9 | 4.7 | 4.1 | 3.8 | 4.5 | 4.5 | 4.4 | 5.3 | 5.7 |
| ម៉ាឡេស៊ី | 5.3 | 0.4 | 1.7 | 3.3 | 3.4 | 3.2 | 2.3 | 1.7 | 1.4 | 1.3 | 1.4 | 1.8 |
| សិង្ហបុរី | 6.5 | 0.5 | 2.9 | 4.7 | 5.5 | 5.5 | 4.9 | 5.2 | 4.2 | 4.0 | 3.6 | 1.6 |
| ថៃ | 5.5 | -0.9 | 3.1 | 4.1 | 4.1 | 4.0 | 3.4 | 2.6 | 2.9 | 3.2 | 3.1 | 2.3 |
| វៀតណាម | 23.3 | 7.3 | 9.0 | 19.4 | 22.5 | 19.8 | 16.0 | 8.6 | 5.6 | 7.0 | 6.9 | 6.6 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 5.9 | -0.8 | 3.2 | 5.7 | 6.3 | 4.6 | 3.8 | 2.9 | 1.9 | 2.1 | 2.4 | 2.4 |
| ហុងកុង | 4.3 | -0.3 | 2.4 | 5.1 | 6.5 | 5.7 | 5.2 | 4.2 | 3.1 | 3.8 | 2.2 | 4.0 |
| កូរ៉េខាងត្បូង | 4.6 | 2.8 | 3.0 | 4.2 | 4.8 | 4.1 | 2.9 | 2.4 | 1.6 | 1.7 | 1.4 | 1.1 |
| តៃវ៉ាន់ | 3.2 | -1.1 | 1.0 | 1.6 | 1.3 | 1.4 | 1.3 | 1.6 | 3.0 | 1.9 | 1.8 | 0.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 3.3 | 0.4 | 1.6 | 2.7 | 2.7 | 2.9 | 2.7 | 2.5 | 2.5 | 2.3 | 1.8 | 1.5 |
| ជប៉ុន | 1.4 | -1.3 | -0.7 | 0.3 | 0.2 | -0.3 | 0.3 | 0.2 | -0.4 | -0.2 | -0.3 | -0.3 |
| សហរដ្ឋអាមេរិក | 3.8 | -0.4 | 1.7 | 3.5 | 3.8 | 3.3 | 2.8 | 1.9 | 1.7 | 1.9 | 1.7 | 1.4 |

Sources: International Monetary Fund, Economist and National Institute of Statistics

## តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | | | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4054.2 | 4140.5 | 4187.1 | 4044.9 | 4095.7 | 4071.9 | 4046.0 | 4054.3 | 4060.2 | 3995.9 | 3995 | 4032.9 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9699.0 | 10413.8 | 9089.9 | 8593 | 8625.8 | 8985.7 | 9078.6 | 9281.3 | 9490.3 | 9614.6 | 9681.9 | 9783.6 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.5 | 3.2 | 3.0 | 3.0 | 3.2 | 3.1 | 3.1 | 3.1 | 3.1 | 3.1 | 3.0 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.4 | 1.5 | 1.4 | 1.2 | 1.2 | 1.3 | 1.3 | 1.3 | 1.6 | 1.2 | 1.2 | 1.2 |
| ថៃ (បាត) | 33.4 | 34.3 | 31.7 | 30.3 | 30.2 | 31.0 | 31.0 | 31.3 | 31.3 | 30.7 | 29.8 | 29.9 |
| វៀតណាម (ដុង) | 16,382.0 | 17,725.2 | 19200.8 | 20,693.6 | 20,699.6 | 20,997.7 | 20,971.2 | 20,849.7 | 20,847.5 | 20,839.3 | 20,829.6 | 20,828.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 6.9 | 6.8 | 6.76 | 6.5 | 6.4 | 6.36 | 6.3 | 6.3 | 6.4 | 6.2 | 6.2 | 6.2 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.77 | 7.8 | 7.8 | 7.78 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1137.2 | 1277.8 | 1156.3 | 1084.3 | 1084.9 | 1144.87 | 1131.2 | 1152.6 | 1132.9 | 1089.9 | 1085.9 | 1123.4 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.5 | 33.0 | 31.3 | 28.9 | 29.2 | 30.26 | 29.7 | 29.6 | 29.8 | 29.2 | 29.5 | 29.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.7 | 0.8 | 0.7 | 0.7 | 0.74 | 0.8 | 0.8 | 0.8 | 0.8 | 0.8 | 0.8 |
| ជប៉ុន (យ៉េន) | 102.5 | 93.6 | 87.8 | 81.7 | 77.9 | 77.78 | 79.3 | 80.1 | 78.6 | 81.3 | 92.3 | 98.8 |

Sources: International Monetary Fund, Economist and National Bank of Cambodia

## តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៨-២០១៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | | | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ពោត (US No. 2) - USA (USD/តោន) | 218.2 | 167.3 | 167.3 | 311.6 | 302.8 | 270.8 | 277.5 | 270.5 | 327.1 | 310.9 | 305.2 | 291.4 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 912.2 | 686.8 | 834.7 | 1147.0 | 1079.0 | 1024.7 | 1106.7 | 1083.3 | 993.0 | 809.3 | 852.7 | 850.3 |
| កៅស៊ូ SMR 5 (USD/តោន) | 2586.3 | 1884.8 | 3152.2 | 4968.8 | 4617.6 | 3658.0 | 3701.2 | 3361.0 | 2799.2 | 2941.5 | 3029.5 | 2497.2 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 615.3 | 524.5 | 456.2 | 514.3 | 581.3 | 610.3 | 549.0 | 600.3 | 595.7 | 597.0 | 607.0 | 570.0 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 460.4 | 414.0 | 375.4 | 525.7 | 514.0 | 454.8 | 490.8 | 546.5 | 649.4 | 577.8 | 558.4 | 569.8 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 95.4 | 60.5 | 71.6 | 113.3 | 108.9 | 109.1 | 117.3 | 106.7 | 106.6 | 107.3 | 109.5 | 100.9 |
| សាំង - US Gulf Coast (សេន/លីត្រ) | 62.2 | 42.9 | 49.8 | 78.7 | 74.6 | 68.5 | 79.0 | 74.0 | 71.6 | 73.4 | 74.8 | 71.2 |
| ម៉ាស៊ូត (ស្តង់ដាតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 76.20 | 43.05 | 51.6 | 75.7 | 77.3 | 77.3 | 83.8 | 77.8 | 81.1 | 80.3 | 81.5 | 75.6 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[១]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ក្នុងត្រីមាសទី២ ឆ្នាំ២០១៣ សេដ្ឋកិច្ចកម្ពុជា បានងើបឡើងវិញពីការធ្លាក់ចុះក្នុងត្រីមាសមុន។ ថ្វីបើនៅមានភាពមិនច្បាស់លាស់ផ្នែកនយោបាយផុសចេញពី លទ្ធផលបោះឆ្នោតថ្នាក់ជាតិនៅខែកក្កដាក្តី ក៏គេរំពឹងថា កម្ពុជានឹងនៅតែមានកំណើនរឹងមាំ។ ធនាគារអភិវឌ្ឍអាស៊ី បានរក្សាការព្យាករណ៍របស់ខ្លួនពីកំណើន ៧,២% ក្នុងឆ្នាំនេះ។ ប៉ុន្តែគេត្រូវដោះស្រាយបញ្ហាប្រឈមផ្នែករចនាសម្ព័ន្ធនៅក្នុងអនុវិស័យចម្បងៗជាច្រើន ជាពិសេសវិស័យកាត់ដេរ និងកសិកម្ម ប្រសិនបើចង់សម្រេចឲ្យបានតាមអត្រាកំណើននេះ។

វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា នៅត្រីមាសទី២ ស្ទុះឡើង ដល់ ២០៩១លានដុល្លារ ធៀបនឹង ២១៩លានដុល្លារនៅត្រីមាសមុន នឹង ២៧៣លានដុល្លារកាលពីមួយឆ្នាំមុន។ កំណើនគួរឲ្យកត់សំគាល់នេះ ទំនងបណ្តាលមកពី កំណើនវិនិយោគក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ ទោះយ៉ាងនេះក្តី វិនិយោគក្នុងវិស័យកាត់ដេរបានធ្លាក់ចុះ ៣០,២% ធៀបនឹងត្រីមាសមុន (២១,៦% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៧៦,៤លានដុល្លារ ដែលទំនងជាដោយសារកត្តាបីយ៉ាងៈ (១) ការធ្វើពិពិធកម្មសេដ្ឋកិច្ចលើកកម្ពស់អនុវិស័យផ្សេងៗទៀត (២) កំណើនភាពងាយរងគ្រោះឡើងវិញនៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប និង (៣) ភាពមិនច្បាស់លាស់ផ្នែកនយោបាយ ដែលអាចប៉ះពាល់ដល់រដ្ឋាភិបាលក្នុងការទទួលបានជំនួយពីបរទេស និងលក្ខខណ្ឌអនុគ្រោះពិសេសផ្សេងៗ។ ដោយសារសេដ្ឋកិច្ចកម្ពុជា មិនទាន់ធ្វើពិពិធកម្មបានច្រើននោះ ការធ្លាក់ចុះនេះទំនងបណ្តាលជាសំខាន់មកពីកត្តាទី២ និង ទី៣។ កូដកម្មជាញឹកញាប់ធ្វើឡើងដោយសហជីព និងសហព័ន្ធសហជីពនានា ទំនងជាបានរាំងស្ទះដល់វិនិយោគថ្មីៗក្នុងអនុវិស័យដ៏សំខាន់ៗទាំងនេះ។ វិនិយោគខាងកសិកម្ម កើនឡើងគួរឲ្យកត់សំគាល់ធៀបនឹងត្រីមាសមុន ប៉ុន្តែធ្លាក់ចុះ ៣០% ធៀបនឹងមួយឆ្នាំមុន ដែលបង្ហាញបញ្ហាប្រឈមមួយចំនួនដល់ការកែលំអភាពប្រកួតប្រជែង និងផលិតភាពក្នុងវិស័យកសិកម្ម ជាពិសេសដំណាំស្រូវ។ វិនិយោគយឺតៗនេះ ក៏អាចប៉ះពាល់ដល់គោលដៅនាំចេញនៅក្នុងគោលនយោបាយស្រូវរបស់រដ្ឋាភិបាលដែរ។

នៅត្រីមាសទី២ វិនិយោគខាងផ្នែកសណ្ឋាគារ និងអាជីវកម្មជាប់ទាក់ទងនឹងទេសចរណ៍ បានកើន ១០០% ធៀបនឹងត្រីមាសមុន ដល់ ១០៦លានដុល្លារ។ កម្ពុជានៅតែបន្ត ទាក់ទាញភ្ញៀវទេសចរឲ្យបានកាន់តែច្រើន ក្នុងនេះ ភ្ញៀវទេសចរបរទេសមកដល់ក្នុងត្រីមាសទី១ បានកើន ២០,៩% បើធៀបនឹងកាលពីមួយឆ្នាំមុន។

ការងើបឡើងវិញ ក្នុងវិស័យសំណង់ដែលជាសសរស្តម្ភមួយនៃកំណើន នៅមានភាពមិនច្បាស់លាស់។ ក្នុងត្រីមាសទី២ តម្លៃអនុមតិគម្រោងសាងសង់សរុបធ្លាក់ចុះ ៣៦,៥% ធៀបនឹងត្រីមាសមុន (១៥,៦% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ២៨២លានដុល្លារ ក្នុងនេះតួលេខសម្រាប់ភូមិគ្រឹះ និងផ្ទះធ្លាក់ចុះ ៩២,៩% (៨៤,៥% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១០,៣លានដុល្លារ ហើយសម្រាប់ផ្ទះល្វែងធ្លាក់ចុះ ៧១,១% (៨៥% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៣៣លានដុល្លារ។

ការនាំចេញក៏បានធ្លាក់ចុះដែរ។ ការនាំចេញសរុបក្នុងត្រីមាសទី២ ធ្លាក់ចុះ ៨,៨% ធៀបនឹងត្រីមាសមុន មកត្រឹម ១៦២០,១លានដុល្លារ។ ផលិតផលកាត់ដេរដែលមានដល់ ៧៧,៧% នៃតម្លៃនាំចេញសរុបបានធ្លាក់ចុះ ១៤,៦% មកត្រឹម ១២៥៩លានដុល្លារ ដែលបណ្តាលឡើងជាសំខាន់ដោយសារមានការនាំចេញតិចជាងមុនទៅសហរដ្ឋអាមេរិក(២៤,៣%) និងសហភាពអឺរ៉ុប (៥,៣%)។ ការនាំចេញផលិតផលកសិកម្ម (មានកៅស៊ូ និងអង្ករជាសំខាន់) បានកើន ៤,១% ធៀបនឹងត្រីមាសមុន (២៧,២% ធៀបនឹងមួយឆ្នាំមុន) ដល់ ១២៨,៩លានដុល្លារ ក្នុងនេះ ការនាំចេញអង្ករកើន ៥០,៦%ធៀបនឹងឆ្នាំមុន ប៉ុន្តែការនាំចេញកៅស៊ូ ឈើ និងត្រី បានធ្លាក់ចុះ។ ក្នុងត្រីមាសទី២ ការនាំចូលសរុបកើន ៤០,២% ធៀបនឹងត្រីមាសមុន (១៧,៣% ធៀបនឹងមួយឆ្នាំមុន) ដល់ ២,២ពាន់លានដុល្លារ។ ការនាំចូលប្រេងសាំងកើន ០,៦% ធៀបនឹងឆ្នាំមុន, ប្រេងម៉ាស៊ូតកើន៨,៦% និងសម្ភារៈសំណង់កើន ២៥,៩%។

## ហិរញ្ញវត្ថុសាធារណៈ

ការបន្តពង្រឹងការប្រមូលពន្ធ និងចំណូលមិនមែនពន្ធ ជាបញ្ហាសំខាន់សម្រាប់រដ្ឋាភិបាល និងសេដ្ឋកិច្ច។ នៅត្រីមាសទី២ ចំណូលសរុបកើន ២១,១% ធៀបនឹងត្រីមាសមុន (៧,៨% ធៀបនឹងមួយឆ្នាំមុន) ដល់ ២២០៥ពាន់លានរៀល ដែលទំនងបណ្តាលពីកំណើនចំណូលចរន្ត ២០,៩% ធៀបនឹងត្រីមាសមុន (១៣,៧% ធៀបនឹងមួយឆ្នាំមុន)។ ចំណូលពន្ធកើន ២៨,៥% (១៧,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ២០២៤ពាន់លានរៀល និងរួមមាន ពន្ធក្នុងស្រុក និងពន្ធលើពាណិជ្ជកម្មអន្តរជាតិ ដែលតំណាងឲ្យប្រមាណ ៩២,៣% នៃចំណូលចរន្តសរុប។ រដ្ឋាភិបាលត្រូវផ្តោតផងដែរ លើការពង្រឹងចំណូលមិនមែនពន្ធ (ឧទាហរណ៍ចំណូលលើទ្រព្យសម្បត្តិ,ការលក់ទំនិញនិងសេវា)ដើម្បីប៉ះប៉ូវលើការថយចុះជាបន្តបន្ទាប់នៃពន្ធលើពាណិជ្ជកម្មអន្តរជាតិ(១៨,៣% នៃចំណូលពន្ធ) ដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មកម្រិតតំបន់ និងទ្វេភាគី។ ម្យ៉ាងទៀតក៏មានសញ្ញាល្អប្រសើរឡើងក្នុងកិច្ចខិតខំកាត់បន្ថយចំណាយរបស់រដ្ឋាភិបាល ដោយចំណាយសរុបក្នុងត្រីមាសទី២ បានធ្លាក់ចុះ ២០,៦% ធៀបនឹងមួយឆ្នាំមុន ហើយចំណាយចរន្តធ្លាក់ចុះ ១,៤%។ ចំណាយលើបៀវត្សរ៍ធ្លាក់ចុះ ១៨,៦% ប៉ុន្តែចំណាយលើឧបត្ថម្ភធន និងជំនួយសង្គមផ្សេងទៀត

---

[១] អត្ថបទនេះរៀបរៀងដោយលោក រិត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

កើន ២៤,៩% ដែលជាសញ្ញាបង្ហាញថា រដ្ឋាភិបាលកំពុងព្យាយាមជៀសវាងស្ថានភាពមានមន្ត្រីរាជការច្រើនពេក។ ចំណាយមូលធនធ្លាក់ចុះ ៦៦,៥% ធៀបនឹងមួយឆ្នាំមុន ដែលប៉ះពាល់ដល់ការកសាង និងថែទាំផ្លូវ ស្ពាន និងអាគាររបស់រដ្ឋ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី២អតិផរណាកើនឡើងបន្តិចប៉ុន្តែស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានត្រឹម ២,២% ធៀបនឹង ១,៥%កាលពីត្រីមាសមុន និង ២,៩%កាលពីមួយឆ្នាំមុន។ សន្ទស្សន៍ថ្លៃស្បៀងនិងភេសជ្ជៈគ្មានជាតិស្រា មានកម្រិត ២,៧% ធៀបនឹង ១,៧% កាលពីត្រីមាសមុន និង ៣,៤% កាលពីមួយឆ្នាំមុន។ ប្រាក់រៀលធ្លាក់ថ្លៃ ១,០% ធៀបនឹងត្រីមាសមុន (កើន ០,៥% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារអាមេរិក។ នៅត្រីមាសទី១ មាសធ្លាក់ថ្លៃ ៤,៦% ធៀបនឹងត្រីមាសមុន (៣,៤% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១៩៧,១ដុល្លារ/ជី។ នៅត្រីមាសទី២ ម៉ាស៊ូតធ្លាក់ថ្លៃ ២,៨% ធៀបនឹងត្រីមាសមុន មកត្រឹម ៤៩៩២រៀល/លីត្រ ប៉ុន្តែឡើងថ្លៃ ១២,០% ធៀបនឹងមួយឆ្នាំមុន។ សាំងចុះថ្លៃ ២,៥% ធៀបនឹងត្រីមាសមុន (០,៦% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៥២៧៤,៥ រៀល/លីត្រ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី១ ឆ្នាំ២០១៣ សាច់ប្រាក់ងាយស្រួលសរុបកើន ៦,៦% ធៀបនឹងត្រីមាសមុន (២២,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ៣០.៤៨១ពាន់លានរៀល ដែលបង្ហាញពីកំណើនឥណទានសម្រាប់វិនិយោគក្នុងអាជីវកម្ម។ ការផ្តល់ឥណទានដល់វិស័យឯកជនកើន ៥,៥% ធៀបនឹងត្រីមាសមុន (៣២,១% ធៀបនឹងមួយឆ្នាំមុន) ដល់ ២៤.៨២០ពាន់លានរៀល។ នៅត្រីមាសដដែល ការផ្គត់ផ្គង់រូបិយវត្ថុកើន ១១,២% (១២,៩% ធៀបនឹងមួយឆ្នាំមុន) ហើយរូបិយវត្ថុផ្សេងៗកើន ៥,៨% (២៤,៤%ធៀបនឹងមួយឆ្នាំមុន)។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ដល់កម្រិតនៃរូបិយវត្ថុក្នុងចរាចរណ៍ ដើម្បីជៀសវាងអតិផរណាជំរុញឡើងដោយរូបិយវត្ថុ ថ្វីបើតួលេខអតិផរណាមិនបានបង្ហាញពីសម្ពាធរុញឡើងបែបនេះក្តី។

## ស្ថានភាពភាពក្រីក្រ

នៅខែសីហា ចំណូលប្រចាំថ្ងៃពិត របស់ពលករពីរក្រុម ក្នុងចំណោមពលករងាយរងគ្រោះទាំង ១០ក្រុម បានធ្លាក់ចុះ បើធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។

អ្នកស៊ីឈ្នួលធ្វើស្រែ រកចំណូលបាន ៧៧២៣រៀល/ថ្ងៃ ឬ ៩,០% តិចជាងកាលពីមួយឆ្នាំមុន ប៉ុន្តែ ២០% ច្រើនជាងកាលពីខែឧសភា ដោយសារមានការធ្លាក់ចុះចំនួនពលករ។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មាន ៥៤% ធ្វើការស្ទើរពេញៗមួយខែ រីឯពលករដទៃទៀតធ្វើការតិចជាងម្ភៃថ្ងៃក្នុងមួយខែ។ ម្យ៉ាងទៀត ៧៧% នៃអ្នកឆ្លើយសម្ភាសន៍បានប្រាប់ថា ប្រាក់ចំណូលរបស់ពួកគេយ៉ាងហោចណាស់ ក៏អាចដោះស្រាយការចំណាយប្រចាំថ្ងៃដែលមានប្រហែល ៥១% នៃប្រាក់ចំណូលនេះ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ ធ្លាក់ចុះ ១,១% ធៀបនឹងឆ្នាំមុន មកត្រឹម ១០.៥៧២រៀល។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់គ្នា ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។ ពួកគេសុទ្ធតែចេញពីខេត្តមករស់នៅក្រុងភ្នំពេញ ហើយភាគច្រើនមកពីខេត្តស្វាយរៀង និងខេត្តតាកែវ។ ក្នុងចំណោមពួកគេ មានតែ ១៨% ប៉ុណ្ណោះដែលស្នាក់នៅផ្ទះជួលរួមគ្នាជាមួយអ្នកធាក់ស៊ីក្លូខ្លះទៀត ហើយចូលលុយគ្នាបង់ថ្លៃឈ្នួលផ្ទះ។ អ្នកធាក់ស៊ីក្លូចំណាយជាមធ្យមអស់ ៨១% នៃប្រាក់ចំណូលសរុបរបស់ខ្លួន។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែងកើន ១៣% ដល់ ១៤.០៧១រៀល ឬ ៩,៧% ខ្ពស់ជាងក្នុងអង្កេតកាលពីខែឧសភា។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់គ្នាស្នាក់នៅផ្ទះជួល និងចូលលុយគ្នាបង់ឈ្នួលផ្ទះ អស់ជាមធ្យម ៥ដុល្លារ/នាក់/ខែ។ អ្នកឆ្លើយសម្ភាសន៍ ៣៣% មករស់នៅក្រុងភ្នំពេញជាមួយគ្រួសាររបស់ខ្លួន។ ពួកគេមានចំណាយប្រចាំថ្ងៃអស់ដល់ ៧២% នៃប្រាក់ចំណូលរបស់ខ្លួន។

អ្នកលក់បន្លែតូចតាចគឺជា ប្រភពប្រាក់ចំណូលចម្បងសម្រាប់គ្រួសាររបស់ខ្លួន។ ចំណូលរបស់ពួកគេបានប្រសើរឡើង បើធៀបនឹងឆ្នាំមុន ប៉ុន្តែធ្លាក់ចុះ ១,៣% ធៀបនឹងខែឧសភា។ អ្នកលក់បន្លែតូចតាច មានចំណាយប្រចាំថ្ងៃស្មើនឹង ៧២% នៃប្រាក់ចំណូលរបស់ខ្លួន។

ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញកើន ២១% ធៀបនឹងឆ្នាំមុន ដល់ ១២.៩៤៤រៀលប៉ុន្តែធ្លាក់ចុះ ៥,៧% ធៀបនឹងក្នុងអង្កេតលើកមុន។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់គ្នាសុទ្ធតែមកពីខេត្ត ក្នុងនេះមាន ៧៨% បានជួលផ្ទះស្នាក់នៅ។ ពួកគេមានចំណាយប្រចាំថ្ងៃស្មើនឹង ៥៨% នៃប្រាក់ចំណូលរបស់ខ្លួន ហើយពុំមានលទ្ធភាពសន្សំប្រាក់ទុកទេ។

អ្នករត់ម៉ូតូឌុបចំនួន ៩០% ជាអ្នកមកពីតាមខេត្ត។ ពួកគេរកចំណូលបានជាមធ្យម ១៣.៥៧៣រៀល/ថ្ងៃ ឬកើន ០,៦% ធៀបនឹងឆ្នាំមុន និង ៨,៤% ធៀបនឹងខែឧសភា។ សម្រាប់ ៩៧% នៃអ្នកឆ្លើយសម្ភាសន៍ ប្រាក់ចំណូលនេះអាចដោះស្រាយការចំណាយប្រចាំថ្ងៃបាន។

អ្នករត់តុភោជនីយដ្ឋានរកចំណូលបាន ៦៧៥០រៀល/ថ្ងៃ ឬកើន ២១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់គ្នាសុទ្ធតែមកពីតាមខេត្ត ហើយម្ចាស់ភោជនីយដ្ឋានបានផ្តល់កន្លែងឲ្យស្នាក់នៅ។ ក្នុងចំណោមពួកគេ មាន ៧៥% ជាប្រភពប្រាក់ចំណូលដ៏សំខាន់ក្នុងគ្រួសារ។ ពួកគេមិនមានលទ្ធភាពសន្សំប្រាក់ទុកទេ។

ប្រាក់ចំណូលរបស់កម្មករកាត់ដេរកើន ៧,៩% ធៀបនឹងឆ្នាំមុន ដល់ ១០.៣៥៧រៀល/ថ្ងៃ។ គ្មានកម្មករឆ្លើយសម្ភាសន៍ណាម្នាក់បានបញ្ចប់ការអប់រំថ្នាក់បឋមសិក្សានោះឡើយ។ ទោះជាយ៉ាងនេះក្តី ក៏មាន ១៩% បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជំនាញមុននឹងទទួលបានការងារនៅក្នុងរោងចក្រ។ ពួកគេធ្វើការ ៦ថ្ងៃ មានសរុប ៥៨ម៉ោង ក្នុងមួយសប្តាហ៍។ ជាមួយប្រាក់ចំណូលនេះ ពួកគេមិនអាចទ្រទ្រង់ជីវភាពគ្រួសារនៅឯស្រុកបានគ្រប់គ្រាន់ទេ។

## តារាង ១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៦-១៣*

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | |
| កសិកម្ម | 498.0 | 135.6 | 92.0 | 615.0 | 530.68 | 725 | 154.7 | 81.2 | 181.1 | 114.6 | 2.3 | 56.8 |
| ឧស្សាហកម្ម | 365.3 | 709.1 | 724.9 | 818.5 | 403.66 | 2860.1 | 208.7 | 173.7 | 245.6 | 196.5 | 195.4 | 1928.3 |
| *កាត់ដេរ* | *89.4* | *170.7* | *142.8* | *90.1* | *122.81* | *393.9* | *139.4* | *97.5* | *107.2* | *152.9* | *109.5* | *76.4* |
| សេវាកម្ម | 2939.1 | 1742.5 | 10,003.2 | 4432.0 | 1337.34 | 3425.4 | 50.9 | 18.0 | 2.1 | 845.6 | 21.2 | 106.0 |
| *សណ្ឋាគារ និងទេសចរណ៍* | *345.0* | *1048.3* | *8758.1* | *3980.1* | *1105.14* | *2850.9* | *50.9* | *0.0* | *0.0* | *640.6* | *0.0* | *106.0* |
| សរុប | 3802.4 | 2587.2 | 10,570.9 | 5865.5 | 2271.7 | 7010.42 | 414.4 | 273.0 | 428.8 | 1156.6 | 218.9 | 2091.1 |
| | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | |
| សរុប | - | - | - | - | - | - | -69 | -33.9 | 55.6 | 169.8 | -81.1 | 855.5 |
| | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | |
| សរុប | 275.6 | 246.6 | 308.6 | -44.5 | -61.3 | 209 | 48.4 | -89.6 | -84.4 | -13.6 | -47.5 | 666.0 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង ២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៦-១៣

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | លានដុល្លារ | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 33.1 | 79.1 | 154.7 | 64.3 | 36.2 | 185.5 | 64.8 | 66.6 | 18.3 | 8.5 | 145.2 | 10.3 |
| ផ្ទះល្វែង | 213.3 | 297.2 | 221.6 | 149.6 | 183.8 | 219.6 | 60.8 | 219.3 | 61.6 | 10.2 | 114.1 | 33.0 |
| ផ្សេងៗ | 76.8 | 259.6 | 740.9 | 227.3 | 269.7 | 199.9 | 197.2 | 47.8 | 94.9 | 41.2 | 154.4 | 238.3 |
| សរុប | 323.3 | 635.8 | 1117.0 | 441.2 | 489.8 | 605.0 | 322.8 | 333.6 | 174.9 | 59.9 | 443.7 | 281.6 |
| | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | |
| សរុប | - | - | - | - | - | - | 117.1 | 3.3 | -47.6 | -65.8 | 590.9 | -36.5 |
| | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | |
| សរុប | -9.9 | 96.7 | 75.7 | -60.5 | 11 | 23.5 | 637.1 | 331.1 | -29.3 | -59.7 | 28.1 | -15.6 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង ៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៦-១៣

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | |
| តាមផ្លូវអាកាស | 33.1 | 79.1 | 1239.4 | 1111.7 | 1304.3 | 1480.4 | 513.6 | 317.1 | 370.5 | 500.7 | 611.2 | 398.1 |
| តាមផ្លូវគោក និងទឹក | 213.3 | 297.2 | 881.9 | 999.7 | 1094.6 | 14014.6 | 481.5 | 424.3 | 450.3 | 506.1 | 560.9 | 522.5 |
| សរុប | 76.8 | 259.6 | 2121.3 | 2111.5 | 2398.9 | 28818.6 | 995.2 | 761.4 | 820.9 | 1006.8 | 1172.1 | 920.5 |
| | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | |
| សរុប | - | - | - | - | - | - | 24.9 | -23.5 | 7.8 | 22.6 | 16.4 | -21.5 |
| | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | |
| សរុប | -9.9 | 96.7 | 5.3 | 0.5 | 13.6 | 20.1 | 27.8 | 25.5 | 17.3 | 26.3 | 17.8 | 20.9 |

Source: Ministry of Tourism

## តារាង ៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៦-១៣*

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 2922.8 | 3161.6 | 3097.8 | 2901.6 | 3630.2 | 4929.5 | 1280.1 | 1775.9 | 1595.8 | 1454.7 | 1576.9 | 1620.1 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2810.8 | 3050.2 | 2986.2 | 2565.3 | 3223.4 | 4259.6 | 1070.8 | 1474.7 | 1329.1 | 1140.83 | 1225.2 | 1258.95 |
| *- សហរដ្ឋអាមេរិក* | 1851.7 | 1959.9 | 1908.3 | 1512.6 | 1853.9 | 2055.3 | 493.3 | 627.3 | 566.6 | 456.07 | 526.8 | 474.62 |
| *- សហភាពអឺរ៉ុប* | 603.0 | 660.9 | 689.0 | 644.7 | 809.5 | 1322.2 | 328.4 | 504.1 | 462.7 | 421.82 | 397.5 | 477.47 |
| *- អាស៊ាន* | 80.4 | 90.3 | 10.76 | 6.9 | 9.9 | 17.63 | 6.4 | 11.7 | 11.4 | 9.76 | 13.0 | 12.66 |
| *- ជប៉ុន* | 40.6 | 30.1 | 25.2 | 44.5 | 86.5 | 146.97 | 50.1 | 48.9 | 47.1 | 42.47 | 57.6 | 51.39 |
| *- ប្រទេសផ្សេងៗ* | 235.1 | 309.0 | 352.9 | 356.5 | 463.6 | 717.5 | 192.5 | 282.7 | 241.3 | 210.71 | 230.3 | 242.81 |
| កសិកម្ម | 59.7 | 55.6 | 44.5 | 73.1 | 164.9 | 362.05 | 80.5 | 101.3 | 86.1 | 108.77 | 123.8 | 128.9 |
| *- កៅស៊ូ* | 41.5 | 41.0 | 35.8 | 51.6 | 89.1 | 197.63 | 40.3 | 46.4 | 46.1 | 43.84 | 36.6 | 38.67 |
| *- ឈើ* | 8.6 | 8.7 | 3.4 | 3.5 | 34.1 | 48.79 | 8.9 | 12.4 | 4.1 | 11.6 | 14.5 | 8.88 |
| *- ត្រី* | 5.9 | 3.2 | 2.3 | 3.9 | 2.8 | 3.12 | 0.5 | 0.7 | 0.4 | 0.4 | 0.3 | 0.5 |
| *- ស្រូវ* | 3.7 | 2.7 | 2.6 | 10.9 | 34.7 | 106.56 | 27.1 | 37.5 | 31.7 | 50.2 | 65.8 | 56.47 |
| *- ផលិតផលកសិកម្មផ្សេងៗ* | 52.3 | 55.8 | 0.5 | 3.0 | 4.1 | 5.95 | 3.9 | 4.4 | 3.9 | 2.8 | 6.6 | 24.41 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | 512.2 | 554.8 | 67.1 | 263.22 | 242.0 | 307.86 | 128.8 | 199.9 | 180.6 | 205.1 | 274.9 | 232.24 |
| ការនាំចូលសរុប | 38.8 | 58.7 | 4272.5 | 4331.5 | 5190.6 | 6375.9 | 1609.2 | 1885.4 | 2015.2 | 1938.2 | 1576.9 | 2211.4 |
| ក្នុងនេះ៖ សាំង | 113.0 | 122.8 | 84.8 | 91.13 | 108.6 | 294.4 | 70.7 | 76.7 | 78.0 | 78.8 | 1225.2 | 77.19 |
| ម៉ាស៊ូត | 56.5 | 69.0 | 19.5 | 180.67 | 203.8 | 447 | 139.4 | 126.6 | 138.3 | 139.9 | 526.8 | 137.44 |
| សម្ភារៈសំណង់ | 303.9 | 304.3 | 56.3 | 49.74 | 57.6 | 48.09 | 13.5 | 14.1 | 16.5 | 16.6 | 397.5 | 17.75 |
| ផ្សេងៗ | 2410.6 | 2606.8 | 4011.8 | 4010 | 4820.6 | 5586.4 | 1386 | 1668.0 | 1782.4 | 1703.0 | 13.0 | 1979 |
| ជញ្ជីងពាណិជ្ជកម្ម | 2922.8 | 3161.6 | -1174.7 | -1429.9 | -1560.5 | -1446.4 | -329.1 | -642.2 | -419.4 | -483.6 | -1606.68 | -591.24 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | -5.2 | -37.7 | -9.9 | -14.2 | 7.4 | 2.8 |
| ការនាំចេញសរុប | - | - | - | - | - | - | -3.3 | 38.7 | -10.1 | -8.8 | 8.4 | 2.7 |
| ការនាំចូលសរុប | - | - | - | - | - | - | -6.0 | 17.2 | 6.9 | -3.8 | 13.1 | 0.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 19.5 | 8.5 | 1.6 | -14.1 | 25.7 | 32.1 | 21.6 | 53.0 | 3.4 | 1.0 | 14.4 | -14.6 |
| ការនាំចេញសរុប | 19.2 | 8.2 | 1.6 | -6.3 | 25.1 | 35.8 | 25.8 | 56.9 | 9.6 | 9.9 | 23.2 | -8.8 |
| ការនាំចូលសរុប | -79.6 | 8.3 | 1.3 | 1.4 | 19.8 | 22.8 | 10.6 | 11.6 | 32.7 | 13.2 | 36.2 | 17.8 |

* Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (web site)

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៦-១៣ ( ពាន់លានរៀល )

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 3259.2 | 1146.1 | 5290.0 | 5988.99 | 2805.83 | 6251.4 | 1728.9 | 2045.1 | 1900.8 | 2017.0 | 1820.2 | 2204.8 |
| ចំណូលចរន្ត | 2881.8 | 1141.6 | 5210.7 | 5859.08 | 2786.12 | 6179.3 | 1725.8 | 1928.6 | 1796.4 | 1993.1 | 1814.3 | 2193.3 |
| ចំណូលពន្ធ | 2270.9 | 965.2 | 4409.9 | 4692.96 | 2457.02 | 5277.5 | 1403.82 | 1721.8 | 1560.7 | 1648.5 | 1575.3 | 2024.1 |
| ពន្ធក្នុងស្រុក | - | 661.8 | 3248.4 | 3533.57 | 1727.10 | 4071.6 | 1092.27 | 1403.4 | 1230.0 | 1277.2 | 1253.1 | 1653.0 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | 303.5 | 1161.5 | 1159.39 | 639.00 | 1205.9 | 311.253 | 318.4 | 330.7 | 371.4 | 322.3 | 371.1 |
| ចំណូលមិនមែនពន្ធ | 610.9 | 176.4 | 800.8 | 1166.13 | 507.13 | 901.8 | 330.98 | 206.9 | 235.7 | 344.6 | 239.0 | 169.2 |
| ចំណូលលើទ្រព្យសម្បត្តិ | - | 13.6 | 78.0 | 291.13 | 4.87 | 63.8 | 91.28 | 13.1 | 22.5 | 16.2 | 8.2 | 18.1 |
| លក់ទំនិញ និងសេវា | - | 124.3 | 424.7 | 460.07 | 268.08 | 588.7 | 166.899 | 171.4 | 132.8 | 196.3 | 152.8 | 137.0 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | 38.5 | 298.2 | 408.91 | 391.70 | 249.3 | 63.8 | 22.4 | 80.5 | 132.1 | 78.0 | 14.0 |
| ចំណូលជាមូលធន | 377.4 | 4.5 | 79.3 | 129.92 | 2019.39 | 72.1 | 3.148 | 116.4 | 104.4 | 23.9 | 5.9 | 11.5 |
| ចំណាយសរុប | 4174.7 | 1689.7 | 6297.8 | 8784.65 | 4259.67 | 9032.4 | 1688.33 | 2425.6 | 2951.3 | 2751.5 | 925.9 | 1925.7 |
| ចំណាយជាមូលធន | 1638.1 | 807.4 | 2574.4 | 2853.23 | 1495.19 | 3546.9 | 699.937 | 716.2 | 1194.5 | 1017.7 | 146.3 | 239.8 |
| ចំណាយចរន្ត | 2536.8 | 882.3 | 3809.0 | 4773.07 | 2848.81 | 5341.2 | 988.398 | 1709.4 | 1756.7 | 1733.9 | 879.6 | 1685.8 |
| បៀវត្សរ៍ | 822.0 | 362.6 | 1397.0 | 2048.81 | 1208.81 | 2170.6 | 508.919 | 725.2 | 657.5 | 595.0 | 395.3 | 590.2 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | 194.2 | 927.1 | 1099.42 | 613.31 | 1518.8 | 189.594 | 514.6 | 462.1 | 420.5 | 247.4 | 642.5 |
| ចំណាយចរន្តផ្សេងទៀត | - | 325.5 | 1384.9 | 1624.84 | 1067.07 | 1651.8 | 289.9 | 469.7 | 637.1 | 718.4 | 236.9 | 453.2 |
| សមតុល្យជាទូទៅ | -915.6 | -543.6 | -1007.8 | -2795.66 | -1453.83 | -1271.4 | 196.5 | -380.6 | -1050.5 | -734.5 | 0.0 | 279.2 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1360.7 | 741.5 | 2055.10 | 1845.21 | 772.81 | -2781.0 | 577.8 | 491.5 | 959.3 | 429.2 | 894.4 | 129.0 |
| ហិរញ្ញប្បទានក្នុងស្រុក | -445.1 | -185.8 | -127.00 | 938.64 | 567.96 | 2379.2 | -565.7 | 148.4 | 22.1 | 62.4 | -44.2 | 0.0 |

Source: MEF web site

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស ( មធ្យមភាគតាមការិយបរិច្ឆេទ ) ២០០៦-១៣

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ( តុលា-ធ្នូ ២០០៦:១០០ ) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ( បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន ) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 4.7 | 5.8 | 19.7 | -0.7 | 4.1 | 5.4 | 2.9 | 2.9 | 1.6 | 1.8 | 1.5 | 2.2 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 6.4 | 9.9 | 33.1 | -0.3 | 4.4 | 6.5 | 3.4 | 3.4 | 1.3 | 1.4 | 1.7 | 2.7 |
| - ដឹកជញ្ជូន | 9.1 | 5.8 | 19.4 | -10.7 | 7.0 | 6.9 | 3.0 | 3.0 | 1.1 | 1.2 | -0.8 | -1 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ ( តាមអត្រាទីផ្សារនៅភ្នំពេញ ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.0 | 4062.7 | 4058.2 | 4140.5 | 4187.1 | 4063.6 | 4046.0 | 4054.3 | 4060.7 | 3995.9 | 3995 | 4033.1 |
| រៀលក្នុង ១ បាតថៃ | 108.7 | 122.8 | 123.5 | 121.1 | 133.13 | 133.2 | 130.2 | 129.0 | 129.3 | 131.3 | 134.7 | 135.74 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.1 | 25.0 | 24.8 | 23.4 | 21.725 | 19.7 | 19.3 | 19.4 | 19.5 | 19.2 | 19.3 | 19.34 |
| ថ្លៃមាស ( ដុល្លារក្នុង១ជី ) | 70.6 | 83.2 | 105.9 | 113.1 | 147.58 | 184.5 | 204.1 | 194.5 | 198.3 | 206.5 | 197.1 | 196 |
| ថ្លៃម៉ាស៊ូត ( រៀល/លីត្រ ) | 3140.0 | 3262.3 | 4555.2 | 3170.9 | 3859.3 | 4761.2 | 5193.9 | 4458.3 | 4983.9 | 5128.8 | 5134.4 | 4992 |
| ថ្លៃសាំង ( រៀល/លីត្រ ) | 4004.0 | 4005.0 | 4750.8 | 3593.1 | 4368.1 | 5044.5 | 5395.8 | 5308.3 | 5251.3 | 5295.4 | 5410.5 | 5274.5 |

Sources: NIS, NBC and CDRI

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៥-១២ ( តួលេខនៅចុងការិយបរិច្ឆេទ )

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 5475.0 | 7224.0 | 10,735.0 | 10,345.0 | 14,655.0 | 16,697.9 | 17893.9 | 18,652.3 | 18,729.6 | 18,463.8 | 18,154.5 | 19,976.7 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -450.0 | -282.0 | 576.0 | 1513.3 | 1573.0 | 2778.9 | | 6211.2 | 7922.3 | 8400.3 | 10437.4 | 10,504.1 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -421.0 | -953.0 | -1816.0 | -2987.0 | -2252.0 | -2126.6 | -2123.1 | -2542.4 | -2399.9 | -2440.6 | -2486.4 | -2991.6 |
| ឥណទានដល់ផ្នែកឯកជន | 2394.0 | 3630.0 | 6386.0 | 9894.0 | 10,532.0 | 13,331.2 | 17552.8 | 18,789.0 | 20,081.4 | 21,398.2 | 23,536.6 | 24,820.2 |
| រូបិយវត្ថុទូទៅ M2 | 5025.0 | 6942.0 | 11,311.0 | 11,858.0 | 16,228.0 | 19,476.8 | 23654.7 | 24,863.5 | 26,651.9 | 26,864.1 | 28,591.9 | 30,480.8 |
| រូបិយវត្ថុ M1 | 1323.0 | 1658.0 | 2052.0 | 2399.0 | 3120.0 | 3220.9 | 3956.2 | 3984.6 | 3871.8 | 3818.2 | 4045.7 | 4500.6 |
| រូបិយវត្ថុផ្សេងៗ | 3702.0 | 5285.0 | 9259.0 | 9459.0 | 13,108.0 | 16,255.9 | 19698.5 | 20,878.9 | 22,780.1 | 23,046.0 | 24,546.2 | 25,980.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 16.1 | 38.1 | 62.9 | 4.8 | 36.9 | 20.0 | 17.8 | 20.2 | 21.1 | 18.6 | 20.9 | 22.6 |
| រូបិយវត្ថុ M1 | 14.7 | 25.3 | 23.8 | 16.9 | 30.1 | 3.2 | 16.9 | 11.4 | 9.4 | 3.7 | 2.3 | 12.9 |
| រូបិយវត្ថុផ្សេងៗ | 16.6 | 42.8 | 75.2 | 2.2 | 38.6 | 24.0 | 17.9 | 22.0 | 23.4 | 21.5 | 44.6 | 24.4 |

Source: National Bank of Cambodia

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ ( ថ្លៃថេរ ខែវិច្ឆិកា ២០០០ )

| | ចំណូលប្រចាំថ្ងៃ ( ជារៀល ) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | 2009 | 2010 | 2011 | 2012 | | 2013 | | | 2013 | | |
| | | | | | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកជាក់ស៊ីក្លូ | 12,628 | 8091 | 9055 | 9532 | 10690 | 10454 | 9588 | 10,681 | 10,572 | 2.2 | -0.0 | -1.1 |
| អ្នកលីសែង | 9005 | 9549 | 9964 | 10,785 | 12,479 | 12,574 | 12,744 | 12,823 | 14,071 | 18.0 | 0.9 | 12.8 |
| អ្នកលក់បន្លែតូចតាច | 9926 | 8273 | 8266 | 8337 | 10,347 | 10,542 | 9949 | 11,571 | 11,421 | -19.1 | 16.9 | 10.4 |
| អ្នករើសអេតចាយ | 4652 | 5857 | 6698 | 8388 | 9139 | 9328 | 9483 | 10,440 | 9561 | 18.7 | 26.3 | 4.6 |
| អ្នកបម្រើតុភោជនីយដ្ឋាន* | 4327 | 4646 | 5607 | 5986 | 5569 | 6436 | 6527 | 6744 | 6750 | 5.6 | 7.7 | 21.2 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 8697 | 6197 | 5691 | 5695 | 8483 | 5000 | 5828 | 6427 | 7723 | 23.8 | -0.1 | -9.0 |
| កម្មកររោងចក្រកាត់ដេរ | 6554 | 7085 | 7746 | 8409 | 9599 | 8989 | 10,000 | 9776 | 10,357 | 16.9 | 13.6 | 7.9 |
| អ្នករត់ម៉ូតូឌុប | 15,691 | 10,685 | 10,623 | 11,568 | 12,807 | 13,042 | 14,427 | 12,522 | 13,573 | 17.7 | -8.0 | 6.0 |
| កម្មករសំណង់គ្មានជំនាញ | 8779 | 8343 | 8790 | 10,307 | 10,690 | 11,375 | 12,548 | 13,728 | 12,944 | 17.7 | 18.5 | 21.1 |
| កម្មករសំណង់មានជំនាញ | 12,710 | 12,487 | 11,952 | 13,159 | 14,029 | 14,270 | 15,156 | 14,136 | 15,726 | 9.6 | 10.0 | 12.1 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

នៅដើមខែសីហា ២០១៣ វិទ្យាស្ថាន CDRI បានទៅចូលរួមការប្រជុំរបស់ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ( UNDP ) ដែលជាការពិគ្រោះយោបល់ជាដំបូងជាមួយអ្នកពាក់ព័ន្ធនានាលើរបាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ២០១៤ ក្រោមប្រធានបទ វិនិយោគក្នុងការអភិវឌ្ឍធនធានមនុស្ស តាមមាគ៌ានៃកំណើនសម្រាប់គ្រប់គ្នា ដែលសង្កត់ធ្ងន់លើការចូលរួមប្រកបដោយប្រសិទ្ធភាព និងភាពជាម្ចាស់នៃស្ថាប័នក្នុងស្រុកនានា។ ក្នុងអំឡុងពេលពីខែកក្កដា ដល់ខែកញ្ញា ២០១៣ វិទ្យាស្ថាន CDRI បានប្រជុំតុមូលដើម្បីរាយការណ៍ពីការងាររបស់ CDRI និងអាទិភាពអភិវឌ្ឍន៍ចម្បងៗរបស់កម្ពុជា ជូនដល់លោកជំទាវ Alison Burrows ជាឯកអគ្គរដ្ឋទូតនៃប្រទេសអូស្ត្រាលី, លោក Paul Keogh ជាទីប្រឹក្សានៃ ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ ( AusAID ) និងលោកស្រី Claire Van der Vaeren ជាអ្នកសម្របសម្រួលប្រចាំប្រទេសនៃ អង្គការសហប្រជាជាតិ/តំណាងប្រចាំប្រទេសនៃ UNDP ។

ក្នុងការប្រជុំពាក់កណ្តាលឆ្នាំកាលពីថ្ងៃទី២៣ សីហា ក្រុមប្រឹក្សាភិបាល CDRI បានស្វាគមន៍ការយល់ព្រមចូលជាសមាជិករបស់ខ្លួន ពីសំណាក់ឥស្សរជន ៣នាក់ថ្មីទៀត ដែលនឹងទទួលតំណែងនេះជាផ្លូវការ នៅពេលប្រជុំពេញអង្គលើកក្រោយនៃក្រុមប្រឹក្សាភិបាល CDRI នៅខែកុម្ភៈ ២០១៤ ខាងមុខ គឺមានបណ្ឌិត Suthad Setboonsarng ប្រធានមូលនិធិ NawachiOne នៅប្រទេសថៃ និងជាអតីតតំណាងពាណិជ្ជកម្មថៃ និងមន្ត្រីជាន់ខ្ពស់នៃអាស៊ាន, លោកស្រី Sandra D'Amico ជានាយកគ្រប់គ្រងនៃក្រុមហ៊ុន HR Inc Cambodia និងជាអនុប្រធាននៃសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា, និងលោកស្រី Eva Mysliwiec ជាប្រធានក្រុមប្រឹក្សាភិបាលនៃអង្គការយុវតារាកម្ពុជា និងជាអតីតនាយកស្ថាបនិកនៃ CDRI ។

កាលពីខែកញ្ញា នាយកប្រតិបត្តិនៃ CDRI បានទៅចូលរួមក្នុង (១) វេទិកាអន្តរជាតិស្តីពី ភាពតភ្ជាប់នៃអាស៊ានបូកបី ដើម្បីសមាហរណកម្មនៅអាស៊ីបូព៌ា: គោលគំនិត និងការប្រមើលឃើញ។ វេទិកានេះរៀបចំឡើងដោយ វិទ្យាស្ថានជាតិនៃយុទ្ធសាស្ត្រអន្តរជាតិ (NIIS) នៃបណ្ឌិតសភាវិទ្យាសាស្ត្រសង្គមចិន (CASS) នៅក្រុងប៉េកាំង ហើយលោកនាយក CDRI បានធ្វើបទបង្ហាញមួយស្តីពី ភាពតភ្ជាប់នៃអាស៊ានបូកបី: ផលប្រយោជន៍សម្រាប់កម្ពុជា និងមហាអនុតំបន់មេគង្គ (GMS) និង